# ប៊ែលធី ទេសចរណ៍

# BELTEI TOUR

*Your Great Delight!*

CAMBODIA
Kingdom of Wonder

# ដំណើរទេសចរណ៍ក្នុងប្រទេស

## សម្រាប់ប្រជាជនកម្ពុជា








## DOMESTIC TOUR PROGRAMS FOR CAMBODIANS










023 9999 20
023 9999 67
017 6789 77
097 38 77777

www.belteitour.com.kh

# ប៊ែលធី គ្រុប BELTEI Group

## ប៊ែលធី សំណង់ BELTEI CONSTRUCTION

សេវាកម្មរួមមាន

- ទិញដី លក់ដី
- ទទួលសង់ សំណង់គ្រប់ប្រភេទ
  - ផ្ទះល្វែង
  - ផ្ទះវីឡា
  - សាលារៀន
  - ផ្សារទំនើប
  - រោងចក្រ

Services Offered

- Buying and Selling Land
- Construction Services:
  - Flats
  - Villas
  - Schools
  - Shopping Malls
  - Factories

## ប៊ែលធី អប់រំ BELTEI EDUCATION

## ប៊ែលធី ទេសចរណ៍ BELTEI TOUR

មានបម្រើសេវា

- ដំណើរទេសចរណ៍ក្នុងប្រទេសសម្រាប់ប្រជាជនកម្ពុជា និងជនបរទេសដែលកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា
- ដំណើរទេសចរណ៍ក្នុងប្រទេសសម្រាប់ភ្ញៀវអន្តរជាតិមកពីប្រទេសនានា
- ដំណើរទេសចរណ៍ទៅក្រៅប្រទេស
- ដំណើរទេសចរណ៍តាមតម្រូវការជាក់លាក់ និងតាមកញ្ចប់
- ដំណើរទេសចរណ៍បែបផ្សងព្រេង បែបលើកទឹកចិត្ត កិច្ចប្រជុំ ឬសន្និសីទ និងពិព័រណ៍
- លក់សំបុត្រយន្តហោះជុំវិញពិភពលោក
- កក់សណ្ឋាគារ
- សេវាកម្មជួយសម្រួលលើទិដ្ឋាការទៅក្រៅប្រទេស ពន្យារ ឬធ្វើលិខិតឆ្លងដែនថ្មី ពន្យាទិដ្ឋាការខ្មែរសម្រាប់ជនបរទេស
- សេវាកម្មពិគ្រោះលើរាល់ការធ្វើដំណើរផ្សេងៗ
- សណ្ឋាគារ និង រមណីយដ្ឋាន

Services Offered

- Domestic Tour Programs for Cambodians & Expatriate
- Inbound Tour Programs (for Foreigner from oversea)
- Outbound Tour Programs (for Cambodian people to visit oversea)
- Tailor made tour and cruises
- Adventures & MICE
- Worldwide Air Ticket
- Hotel Reservation
- Visa, passport arrangement & Cambodian Visa extension
- Travel consulting service
- Hotel and Resort

## វិទ្យាស្ថាន ប៊ែលធី អន្តរជាតិ BELTEI INTERNATIONAL INSTITUTE

មានបង្រៀន៥កម្មវិធីធំៗ

I. ចំណេះទូទៅ (ថ្នាក់ទី ១-១២)
II. ភាសាអង់គ្លេសទូទៅ (គ្រប់កម្រិត)
III. មហាវិទ្យាល័យភាសាបរទេស
IV. វគ្គបណ្តុះបណ្តាលកុំព្យូទ័រ
V. ថ្នាក់ត្រៀមប្រឡងតេស្តអន្តរជាតិ

Five Main Programs Offered

I. Khmer General Education (Grade 1-12)
II. English as a Second Language (Preschool-Level 12)
III. Faculty of Foreign Languages
IV. Computer Training Courses
V. International Test Preparation Courses

## សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ BELTEI INTERNATIONAL UNIVERSITY

ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន-បរិញ្ញាបត្រ-អនុបណ្ឌិត-បណ្ឌិត
មាន ៦ មហាវិទ្យាល័យ

១. មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម
២. មហាវិទ្យាល័យ អប់រំ សិល្បៈ និងមនុស្សសាស្ត្រ
៣. មហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
៤. មហាវិទ្យាល័យ ទេសចរណ៍ និងបដិសណ្ឋារកិច្ច
៥. មហាវិទ្យាល័យ វិស្វកម្ម និងស្ថាបត្យកម្ម
៦. មហាវិទ្យាល័យ ព័ត៌មានវិទ្យា និងវិទ្យាសាស្ត្រ

Foundation Year - Bachelor - Master - PhD
6 Faculties

1. Faculty of **B**usiness Administration
2. Faculty of **E**ducation, Arts and Humanities
3. Faculty of **L**aw and Social Sciences
4. Faculty of **T**ourism and Hospitality
5. Faculty of **E**ngineering and Architecture
6. Faculty of **I**nformation Technology and Science

## ប៊ែលធី ទំនាក់ទំនង អន្តរជាតិ BELTEI INTERNATIONAL RELATIONS

មានបម្រើសេវា

- ការបញ្ជូនសិស្សទៅសិក្សាក្រៅប្រទេស
- កម្មវិធីផ្លាស់ប្តូរនិស្សិត
- ការធ្វើកម្មសិក្សានៅក្រៅប្រទេស

Services Offered

- Overseas Study Service
- Student Exchange Program
- Field Study

# ដំណើរទេសចរណ៍ក្នុងប្រទេសសម្រាប់ប្រជាជនកម្ពុជា

# DOMESTIC TOUR PROGRAMS FOR CAMBODIANS



## មាតិកា


សារស្វាគមន៍ពីអគ្គនាយកប៊ែលធីគ្រុប...........................................2

គោលបំណង ចក្ខុវិស័យ បេសកកម្ម និងគោលដៅ....................3

ព័ត៌មានសង្ខេបអំពីព្រះរាជាណាចក្រកម្ពុជា....................................4

សៀមរាប ៣ថ្ងៃ ២យប់ ...........................................................6

ភ្នំពេញ-កំពង់ធំ-សៀមរាប ៣ថ្ងៃ ២យប់.................................7

សៀមរាប-ភ្នំគូលែន-បន្ទាយស្រី ៤ថ្ងៃ ៣យប់ ...........................8

ប្រាសាទព្រះវិហារ ៣ថ្ងៃ ២យប់ ...............................................9

កោះកុង ៣ថ្ងៃ ២យប់ ...............................................................10

ក្រុងព្រះសីហនុ-កោះឫស្សី-កោះទន្សាយ ៣ថ្ងៃ ២យប់ ...............11

ភ្នំបូកគោ-កែប-ក្រុងព្រះសីហនុ ៣ថ្ងៃ ២យប់...........................12

បាត់ដំបង ៣ថ្ងៃ ២យប់...........................................................13

ភ្នំពេញ-បាត់ដំបង-ប៉ៃលិន ៣ថ្ងៃ ២យប់...................................14

មណ្ឌលគិរី ៣ថ្ងៃ ២យប់..........................................................15

រតនគិរី ៣ថ្ងៃ ២យប់...............................................................16

ក្រចេះ-ឡាវ-រតនគិរី ៤ថ្ងៃ ៣យប់.........................................17

ក្រចេះ-កោះទ្រង់-រតនគិរី ៤ថ្ងៃ ៣យប់...................................18

សេវាលិខិតឆ្លងដែន................................................................19

ដំណើរទេសនាចរណ៍ខ្លីៗជុំវិញភ្នំពេញ ទន្លេបាទី ភ្នំជីសូរ ...............19

សំបុត្រយន្តហោះ.....................................................................20


## Contents


Welcome message from Director-General of BELTEI Group ...2

Purpose, Vision, Mission, and Goals ....................................3

Brief Information on the Kingdom of Cambodia ................5

Siem Reap 3Days 2Nights ..................................................6

Phnom Penh-Kampong Thom-Siem Reap 3Days 2Nights ...7

Siem Reap - Kulen - Banteay Srei 4Days 3Nights ................8

Preah Vihear Temple 3Days 2Nights.................................9

Koh Kong 3Days 2Nights.....................................................10

Sihanoukville-Bamboo Island-Rabbit Island 3Days 2Nights ...11

Bokor - Kep - Sihanoukville 3Days 2Nights .......................12

Battambang 3Days 2Nights ..............................................13

Phnom Penh - Battambang - Pailin 3Days 2Nights ...........14

Mondulkiri 3Days 2nights..................................................15

Ratanakiri 3Days 2Nights.................................................16

Kratie - Laos - Ratanakiri 4Days 3nights...........................17

Kratie - Koh Trong - Ratanakiri 4Days 3nights..................18

Passport Arrangement .......................................................19

Daytrip: Tonle Bati, Phnom Chiso, Phnom Ta Mao ............19

Air Tickets ...........................................................................20




## សារស្វាគមន៍ពីអគ្គនាយកប៊ែលធីគ្រុប



សូមគោរព និងសូមស្វាគមន៍ចំពោះ សម្តេច ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា និងសិស្ស-និស្សិតទាំងអស់ ដែលបានផ្តល់ការទុកចិត្ត និងធ្វើដំណើរទេសចរណ៍ តាមរយៈប៊ែលធីទេសចរណ៍ ដែលជាផ្នែកមួយរបស់ ប៊ែលធីគ្រុប។

ដូចយើងបានដឹងរួចមកហើយថា ព្រះរាជាណាចក្រអច្ឆរិយៈរបស់យើង សំបូរទៅដោយកេរ្តិ៍តំណែលមានតំលៃជាច្រើនដូចជា ប្រពៃណី វប្បធម៌ ជាតិដ៏ត្រចះត្រចង់ ដែលមានប្រវត្តិសាស្ត្រដ៏យូរលង់ និងធនធានធម្មជាតិ សម្បូរបែប។ ជាលទ្ធផលប្រទេសយើងជាប់ក្នុងចំណាត់ថ្នាក់ជាប្រទេសដែល មានការរីកលូតលាស់យ៉ាងឆាប់រហ័សលើវិស័យទេសចរណ៍ ជាពិសេសបាន ជាប់ក្នុងចំណាត់ថ្នាក់ជាទីក្រុងស្អាត និងសមុទ្រស្អាត។ រួមជាមួយនិងការ ខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាកម្មបន្ថែមជូនទៅដល់សិស្ស-និស្សិត បុគ្គ-លិកអង្គការ ក្រុមហ៊ុន មន្ត្រីរាជការ និងប្រជាជនទូទៅ គណៈគ្រប់គ្រង ប៊ែលធីគ្រុប មានសេចក្តីសោមនស្សរីករាយជំរាបជូនពីការបើកឡើងនូវ សេវាថ្មីមួយទៀតរបស់ប៊ែលធីគ្រុបគឺ ប៊ែលធីទេសចរណ៍។

ប៊ែលធីទេសចរណ៍ មានភារកិច្ចក្នុងការផ្តល់ជូននូវសេវាកម្មល្អៗ សម្រាប់ការធ្វើដំណើរកំសាន្តដូចជា ដំណើរកំសាន្តទៅតំបន់ទេសចរណ៍ នានា នៅក្នុងប្រទេស និងក្រៅប្រទេស ការកក់សណ្ឋាគារ សំបុត្រយន្ត ហោះ មធ្យោបាយធ្វើដំណើរ មគ្គុទ្ទេសក៍ និងកញ្ចប់ទេសចរណ៍ ទៅតាម តម្រូវការរបស់លោកអ្នក។

សៀវភៅព័ត៌មានសម្រាប់ទេសចរណ៍ក្នុងស្រុក ដែលលោកអ្នក កំពុងកាន់នេះ មានកម្មវិធីល្អៗទៅកាន់តំបន់ជាច្រើនទូទាំងប្រទេសដូចជា មណ្ឌលគីរី រតនគីរី ក្រចេះ ស្ទឹងត្រែង សៀមរាប ព្រះវិហារ បាត់ដំបង ប៉ៃលិន កោះកុង ក្រុងព្រះសីហនុ កំពត និងក្រុងកែបជាដើម។ តំបន់ ទាំងនោះ សុទ្ធតែជាតំបន់ដ៏មនោរម្យ និងជាទីទាក់ទាញអ្នកទេសចរទាំង ឡាយឱ្យមានអារម្មណ៍ស្រស់ថ្លាជាមួយធម្មជាតិដ៏ត្រកាល និងសម្បត្តិវប្បធម៌ ដ៏សម្បូរបែប។ សេវាកម្មយើងខ្ញុំមានអ្នកបើកបរប្រកបដោយការប្រុងប្រយ័ត្ន ខ្ពស់ មគ្គុទ្ទេសក៍រួសរាយរាក់ទាក់ យល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជា ស្ថានភាព តាមតំបន់ ភោជនីយដ្ឋានមានអាហារឆ្ងាញ់ពិសា អនាម័យល្អ ប្រកបដោយ សុខភាព។ ចំណែកឯការស្នាក់នៅវិញ គឺស្ថិតក្នុងសណ្ឋាគារដែលប្រកប ដោយផាសុកភាព។

ទន្ទឹមនឹងនេះ យើងក៏មានរៀបចំកម្មវិធីដំណើរទេសចរណ៍តាម តម្រូវការផ្សេងៗរបស់លោកអ្នកផងដែរ។ សូមអញ្ជើញទំនាក់ទំនងមកការិ-យាល័យប៊ែលធីទេសចរណ៍ ដើម្បីប្រឹក្សាយោបល់អំពីដំណើរកំសាន្តរបស់ លោកអ្នក ហើយបុគ្គលិកយើងខ្ញុំ រង់ចាំទទួលស្វាគមន៍ដោយក្តីរីករាយដើម្បី ជួយរៀបចំដំណើរទេសចរណ៍របស់លោកអ្នកអោយបានល្អប្រសើរបំផុត។

ប៊ែលធីទេសចរណ៍ សេវាល្អ ជាទីរីករាយរបស់លោកអ្នក!

សូមអរគុណ

អគ្គនាយកប៊ែលធីគ្រុប



**លី ឆេង**

## Welcome Message From Director-General of BELTEI Group

First of all, I would like to express my greatest respect and welcome to Samdech, Your Excellencies, Lok Oknha, Lok Chumteav, all dear students Ladies and Gentlemen who have confidence in our services and have selected BELTEI Tour, which is a subsidiary of BELTEI Group.

As we have already known; Cambodia, the Kingdom of Wonder is abundant in precious heritage such as tradition, brilliant culture, long history, and a lot of natural resources. As a result Cambodia has become a rapidly growing country in terms of its tourism sector, especially for its clean cities and beautiful bays. In our effort to provide more services to our students, staff of organizations and companies, government officials, and the general public, the management of BELTEI Group has a great pleasure to announce the opening of its new BELTEI Tour Services.

BELTEI TOUR is obliged to offer services of the highest quality for traveling, such as touring to local and international destinations, hotel booking, air tickets reservation, transportation, tour guides, and a complete packaged-tour according to your needs.

This local tour booklet you are reading has a lot of programs for tour destinations throughout the country, such as Mondulkiri, Ratanakiri, Kratie, Stung Treng, Siem Reap, Preah Vihear, Battambang, Pailin, Koh Kong, Sihanoukville, Kampot, and Kep city. All those destinations are cordial and attractive for tourists with beautiful nature and abundant culture. We assure our services with careful and skilful drivers, friendly tour guides who know about Cambodian history, destinations' situations, and restaurants which cater delicious meals in clean, hygienic and convenient atmosphere. Accommodations selected are in comfortable hotels.

Meanwhile, we also provide tailor-made tour itineraries for your needs. Kindly contact us at our Tour Office to consult about your traveling. Our staffs are looking forward to giving you a warm welcome in order to prepare the best trip for you.

BELTEI Tour is your great delight with the best service!

Yours Sincerely,

H.E. Ly Chheng

Director-General of BELTEI Group

# គោលបំណង ចក្ខុវិស័យ បេសកកម្ម និងគោលដៅ

## គោលបំណង

ប៊ែលធីគ្រុបបានបង្កើតប៊ែលធីទេសចរណ៍នេះឡើង គឺដើម្បីរួមចំណែកលើកកំពស់វិស័យទេសចរណ៍នៅកម្ពុជា ឱ្យកាន់តែប្រសើរឡើងថែមទៀត ជាមួយរាជរដ្ឋាភិបាលដែលមានក្រសួងទេសចរណ៍ជាសេនាធិការ។ ប៊ែលធីទេសចរណ៍ មានភារកិច្ចនាំភ្ញៀវជាតិ និងអន្តរជាតិ ឱ្យស្គាល់អំពីសម្បត្តិវប្បធម៌ដ៏សំបូរបែបរបស់កម្ពុជារួមមាន ទឹកដី ធម្មជាតិ ប្រាង្គប្រាសាទដ៏ល្អឥតខ្ចោះ និងឆ្នេរសមុទ្រដ៏ស្រស់ត្រកាលដែលជាសមាជិកនៃក្លឹបឆ្នេរសមុទ្រដ៏ស្អាតជាងគេបំផុតនៅលើសកលលោក។ ម្យ៉ាងវិញទៀត ប៊ែលធីទេសចរណ៍មានភារកិច្ចនាំប្រជាជនកម្ពុជា ទៅកំសាន្តនៅតំបន់ទេសចរណ៍នានាលើពិភពលោក ដើម្បីឱ្យបានស្គាល់អំពី វប្បធម៌ និងស្ថានភាពទូទៅ ហើយដកស្រង់យកបទពិសោធន៍នៃការរីកចំរើនរបស់ប្រទេសទាំងនោះ មកច្នៃប្រឌិតដើម្បីអភិវឌ្ឍខ្លួនឯង និងសង្គមជាតិកម្ពុជាឱ្យកាន់តែរីកចំរើនទៅអនាគត។

## ចក្ខុវិស័យ

ប៊ែលធីទេសចរណ៍ នឹងក្លាយទៅជាក្រុមហ៊ុនមួយដែលល្បីឈ្មោះជាងគេ នៅក្នុងការបំរើសេវាកម្មផ្នែកទេសចរណ៍ទាំងក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស ព្រមទាំងត្រូវបានទទួលស្គាល់ទូទាំងពិភពលោក។

## បេសកកម្ម

ដើម្បីឱ្យសំរេចបាននូវចក្ខុវិស័យខាងលើ ប៊ែលធីទេសចរណ៍ យើងខ្ញុំបានរៀបចំសម្ភារទំនើបៗ និងមានបេសកម្មដូចខាងក្រោម៖

- នាំអ្នកទេសចរទាំងអស់ ដែលរួមមានជនជាតិខ្មែរ និងជនជាតិបរទេស ឱ្យស្គាល់ និងយល់ដឹងយ៉ាងច្បាស់អំពី វប្បធម៌ អរិយធម៌ ទំនៀមទំលាប់ ប្រពៃណី សាសនា ទឹកដី សមុទ្រ ប្រាង្គប្រាសាទដ៏ល្អឥតខ្ចោះ ព្រមទាំងទីតាំងទេសចរណ៍សំខាន់ៗក្នុងប្រទេស។
- ក្រុមហ៊ុនបានរៀបចំរថយន្តទំនើបៗ អ្នកបើកបរប្រកបដោយជំនាញ និងមានវិជ្ជាជីវៈ ព្រមទាំងបទពិសោធន៍គ្រប់គ្រាន់។
- អ្នកនាំភ្ញៀវមានអត្តចរិតសុភាពរាបសារ យល់ដឹងពីប្រវត្តិសាស្ត្រ និងតំបន់រមណីយដ្ឋានច្បាស់លាស់ ដែលអាចរៀបរាប់ជូនលោកអ្នកបានយ៉ាងល្អប្រសើរ។
- ជ្រើសរើសសណ្ឋាគារ ដែលមានបរិស្ថានប្រកបដោយផាសុកភាព និងភោជនីយដ្ឋានដែលមានម្ហូបអាហារឆ្ងាញ់ៗ ព្រមទាំងជ្រើសរើសតំបន់ទេសចរណ៍ល្អៗសម្រាប់តម្រូវការរបស់ភ្ញៀវទេសចរ។
- បំរើសេវាលិខិតឆ្លងដែន ដូចជាធ្វើលិខិតឆ្លងដែនថ្មី ពន្យាលិខិតឆ្លងដែន និងបិទរូបថតកូនលើលិខិតឆ្លងដែន។
- លក់សំបុត្រយន្តហោះក្នុង និងក្រៅប្រទេស ទៅកាន់ប្រទេសនានាទូទាំងពិភពលោក។

## គោលដៅ

ដោយមានចក្ខុវិស័យ និងបានរៀបចំបេសកកម្មយ៉ាងប្រុងប្រយ័ត្ន និងមានបុគ្គលិកបំរើការយ៉ាងល្អប្រសើរ យើងសង្ឃឹមជឿជាក់ថា ភ្ញៀវទេសចរ ដែលបានធ្វើដំណើរតាមប៊ែលធីទេសចរណ៍នឹងទទួលបាននូវអារម្មណ៍ស្រស់ថ្លា សប្បាយរីករាយ យល់ដឹងអំពីតំបន់ប្រវត្តិសាស្ត្រនានា និងធ្វើឱ្យអ្នកទាំងនោះ កាន់តែស្រឡាញ់ជាតិមាតុភូមិរបស់ខ្លួនបន្ថែមទៀត និងមានមោទនភាពជាតិដែលបានកើតក្នុងទឹកដីអង្គរដ៏បវរ។

ប៊ែលធីទេសចរណ៍ សេវាល្អ ជាទីរីករាយរបស់លោកអ្នក!

# Purpose, Vision, Mission, and Goals

## PURPOSE

BELTEI Group established BELTEI Tour to contribute and improve Tourism Sector in Cambodia with the Royal Government that has the Ministry of Tourism as its general headquarter. BELTEI Tour has the duty to guide local and international tourists and inform about the abundant treasures and culture of Cambodia including territory, nature, exquisite temples, and beautiful bays, which have become a member of the most beautiful bays in the world Club. Moreover, BELTEI Tour has the duty to guide Cambodian people to visit other tour destinations around the world in order to know about the general situations and to extract experiences from those developed countries for steadily innovating and developing ourselves and the society of Cambodia in the future.

## VISION

BELTEI Tour will become the most well-known company in tour services in both Cambodia and foreign countries, and it will be recognized all over the world.

## MISSION

To achieve the above vision, BELTEI Tour equips modern equipment and has the mission below:

- Guiding local and international tourists and informing clearly about culture, civilization, customs, tradition, religion, territory, bays, exquisite temples and other important tour destinations in the country.
- The company has modern buses and skillful-personal drivers with adequate experiences in driving.
- Guides have modest behavior; they know history and resorts clearly, and they can serve you well.
- Selecting a comfortable-environmental hotel and a high class restaurant; selecting the best tour destinations for your desire.
- Passport services: To prepare a new passport, to extend a passport, and to attach a child's photo on the passport.
- Selling air tickets for domestic and countries overseas around the world.

## GOALS

Having the above vision, preparing the mission carefully, and having good serving staff, we hope and believe that tourists who travel with BELTEI Tour will enjoy and have a pleasant experience; they will know the historical destinations and love their own country more, and will be proud of being born in their wonderful Angkorian territory.

BELTEI Tour is your great delight with the best service!

# ព័ត៌មានសង្ខេបអំពីព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសដ៏ចំណាស់មួយនៅអាស៊ីអាគ្នេយ៍នៃឧបទ្វីបឥណ្ឌូចិន ដែលមានវប្បធម៌អារ្យធម៌ល្បីល្បាញ និងបានបែងចែកជា ១៣ សម័យកាលសំខាន់ៗដូចជា:

១. សម័យនគរភ្នំ ឬហ្វូណន (ស.វទី១ ដល់ឆ្នាំ ៥៥០)
២. សម័យចេនឡា (៥៥០ - ៨០២)
៣. សម័យអង្គរ (៨០២ - ១៤៣២)
៤. សម័យចតុមុខ (១៤៣២ - ១៥១៦)
៥. សម័យលង្វែក (១៥១៦ - ១៥៩៣)
៦. សម័យឧត្តុង្គ (១៦២០ - ១៨៦៣)
៧. សម័យអាណានិគមបារាំង (១៨៦៣ - ១៩៥៣)
៨. សម័យសង្គមរាស្ត្រនិយម (១៩៥៣ - ១៩៧០)
៩. សម័យសាធារណៈរដ្ឋខ្មែរ (លន់ ណល់) (១៩៧០ - ១៩៧៥)
១០. សម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុល ពត) (១៩៧៥ - ១៩៧៩)
១១. សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ - ១៩៨៩)
១២. សម័យរដ្ឋកម្ពុជា (១៩៨៩ - ១៩៩៣)
១៣. ព្រះរាជាណាចក្រកម្ពុជាអាស្រ័យរដ្ឋធម្មនុញ្ញ (១៩៩៣ - បច្ចុប្បន្ន)

ប្រទេសកម្ពុជាមានផ្ទៃដីសរុបចំនួន ១៨១,០៣៥គម$^2$ បែងចែកជា ២៣ខេត្ត ២៦ក្រុង រាជធានី១ (ភ្នំពេញ) និងមាន ៩ខណ្ឌ ២០៤សង្កាត់ ១៥៩ស្រុក ១,៤១៧ឃុំ ១៤,០៧៣ភូមិ ហើយមានប្រជាជនសរុបប្រហែល ១៤លាននាក់ ដែលមានដង់ស៊ីតេ ៧៧នាក់/គម$^2$ និងមាន ព្រំប្រទល់ខាងកើតនិងខាងត្បូងជាប់នឹងប្រទេសវៀតណាម ខាងលិចនិងខាងជើងជាប់ប្រទេសថៃ ខាងជើងជាប់នឹងប្រទេសឡាវ និងទិសនិរតីជាប់ឈូងសមុទ្រថៃ។

ប្រទេសកម្ពុជាទទួលរងនូវអាកាសធាតុត្រូពិចក្ដៅហើយសើម ទើបមានរដូវពីរ គឺរដូវប្រាំង និងរដូវវស្សា ដែលរដូវប្រាំងចាប់ពីខែវិច្ឆិកាដល់ខែមេសា មានសីតុណ្ហភាពពី ២៤ºC-៣៣ºC និងរដូវវស្សាចាប់ពីខែឧសភាដល់ខែតុលា មានសីតុណ្ហភាពពី ១៨ºC-៣០ºC។ អាកាសធាតុត្រជាក់បំផុតនៅខែមករា និងក្ដៅបំផុតនៅខែមេសា។ កំពស់ទឹកភ្លៀងប្រចាំឆ្នាំពី ១០០-១៥០សង់ទីម៉ែត្រ។

ប្រទេសកម្ពុជាគឺជាសមាជិកទី១០ នៃប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។

## ការគ្រប់គ្រងរដ្ឋ

ប្រទេសកម្ពុជាបែងចែកជា ៤ ស្ថាប័នធំៗគឺ ស្ថាប័នព្រះមហាក្សត្រ ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការ និងអនុវត្តនយោបាយលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយមានអាណត្តិ ៥ឆ្នាំបោះឆ្នោតម្តង ដែលការបោះឆ្នោតនោះរួមមាន ការបោះឆ្នោតអសកល និងសកល។ ការបោះឆ្នោតអសកល គឺប្រជាជនបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ហើយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានជាប់ឆ្នោត មានសិទ្ធបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។ ចំណែកឯការបោះឆ្នោតសកលវិញ គឺប្រជាជនបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ហើយសមាជិករដ្ឋសភាដែលឈ្នះឆ្នោតមានសិទ្ធបង្កើតរាជរដ្ឋាភិបាល។

**-ស្ថាប័នព្រះមហាក្សត្រ:** ព្រះមហាក្សត្រសោយរាជ្យជាអធិបតី តែមិនកាន់អំណាច ដែលបានជ្រើសតាំងឡើងតាមរយៈក្រុមប្រឹក្សារាជបល្ល័ង្ក ដោយមានសមាជិក ៩រូប គឺប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សម្តេចព្រះសង្ឃរាជទាំងពីរគណៈ (មហានិកាយ និងធម្មយុត្តិ) អនុប្រធានទាំង២របស់ព្រឹទ្ធសភា និងរដ្ឋសភា។ ព្រះមហាក្សត្រដែលជ្រើសតាំងឡើងត្រូវមានព្រះជន្មចាប់ពី ៣០ ព្រះវស្សាឡើងទៅ និងស្ថិតនៅក្នុងខ្សែរាជវង្ស អង្គឌួង នរោត្តម និងស៊ីសុវត្ថិ។

**-ស្ថាប័ននីតិប្បញ្ញត្តិ:** រួមមានស្ថាប័នព្រឹទ្ធសភា ដែលមាន ៦៣អសនៈ និងស្ថាប័នរដ្ឋសភា ដែលមានចំនួន ១២៣អសនៈ កើតឡើងដោយការបោះឆ្នោតសកល និងអសកល។

**-ស្ថាប័ននីតិប្រតិបត្តិ:** ដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា ដែលបោះឆ្នោតតែងតាំងឡើងដោយរដ្ឋសភាតាមនីតិកាលនីមួយៗ ដោយយកសម្លេង ៥០%+១ ហើយរាជរដ្ឋាភិបាលត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញដែលសភាបានសម្រេច។ រាជរដ្ឋាភិបាលមាន ទីស្តីការនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) ទីស្តីការគណៈរដ្ឋមន្ត្រី (វិមានមិត្តភាព) និងមានក្រសួងចំនួន ២៥ អាជ្ញាធរជាតិចំនួន ១១ រដ្ឋលេខាធិការដ្ឋានចំនួន ២ ស្ថិតនៅក្រោមឱវាទ។

**-ស្ថាប័នតុលាការ:** ជាអង្គនីតិវិនិច្ឆ័យ ដែលរួមមាន តុលាការខេត្ត-ក្រុង ឬសាលាដំបូង សាលាឧទ្ធរណ៍ តុលាការកំពូល និងមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ហើយព្រះអង្គមានសិទ្ធិលើកលែងទោសចំពោះពិរុទ្ធជន។

**កំណើនសេដ្ឋកិច្ចជាតិ** (GDP) នៃប្រទេសកម្ពុជាមានចំនួន ៧% នៅឆ្នាំ២០១១ បានមកពីវិស័យសំខាន់ៗដូចជា:

**-វិស័យអចលនទ្រព្យ និងសំណង់:** ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះវិស័យអចលនទ្រព្យរួមមាន ដីធ្លី ផ្ទះសម្បែង សំណង់ផ្សេងៗបានរីកដុះដាលយ៉ាងឆាប់រហ័ស មានសណ្ឋាគារធំៗ អគារខ្ពស់ៗ សម្រាប់ជួល ឬលក់ និងមានក្រុមហ៊ុនជាច្រើនបានទិញដីធ្វើជាបុរីសង់ផ្ទះរាប់រយល្វែង ហើយលក់ក្នុងតម្លៃថោកសមរម្យនៅតាមតំបន់ពាណិជ្ជកម្មមួយចំនួន ដែលធ្វើឱ្យប្រជាជនមានលទ្ធភាពទិញ ហើយរាជធានីភ្នំពេញ និងខេត្តទាំងនោះបានពង្រីកខ្លួនបានយ៉ាងឆាប់រហ័ស។

**-វិស័យពាណិជ្ជកម្ម:** រួមមានការនាំចេញនូវផលិតផលសំលៀកបំពាក់ទៅកាន់ទីផ្សារអន្តរជាតិ សហរដ្ឋអាមេរិច សហគមន៍អឺរ៉ុប និងផលិតផលកសិកម្មផ្សេងៗទៀតដូចជា កៅស៊ូ អង្ករ ដំឡូងមី។ ផ្នែកនាំចូលរួមមានសម្ភារសំណង់ ដែក ស៊ីម៉ង់ និងយានយន្ត ព្រមទាំងសម្ភារប្រើប្រាស់ជាច្រើនទៀត។

**-វិស័យឧស្សាហកម្ម:** រួមមានការវិនិយោគលើវិស័យកាត់ដេរ ដែលមានរោងចក្រប្រមាណជា ៣០០ រោងចក្រ និងមានកម្មករ-កម្មការិនីជាង ៤០០,០០០នាក់ និងមានរ៉ែប្រេងកាតនៅសមុទ្រ និងវារីអគ្គិសនីនៅ ភ្នំកំចាយ គីរីរម្យ ស្ទឹងតាតៃ។

**-វិស័យកសិកម្ម:** មានប្រជាជន ៨០% បង្កបង្កើនផលលើ ដំណាំស្រូវ ដំណាំហូបផ្លែ ដំណាំឧស្សាហកម្ម និងមានព្រៃសម្បទាន ព្រៃស្ពុក ព្រៃស្រោង ដែលជាជម្រកសត្វព្រៃ និងទាក់ទាញទឹកភ្លៀង។ ចំណែកផ្នែកជលផលរួមមាន ការនេសាទទឹកសាប ការនេសាទសមុទ្រ និងវារីវប្បកម្ម។

**-វិស័យគមនាគមន៍:** បែងចែកជា ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស។

- ផ្លូវគោក: រួមមានផ្លូវជាតិធំៗចំនួន ៧ខ្សែ តភ្ជាប់ពីរាជធានីភ្នំពេញទៅគ្រប់ខេត្តក្រុង គ្រប់តំបន់ទូទាំងប្រទេសដែលមានប្រវែងសរុប ៣៨,២៥៧គម និងមានស្ពានអាកាសពីរ មុនីវង្ស និង៧មករា ស្ពានភ្លោះមុនីវង្ស ជ្រោយចង្វា ស្ពានព្រែកក្ដោ ព្រែកក្ដាម ព្រែកតាម៉ាក់ គីស៊ូណា សេកុង (ស្ទឹងត្រែង) អ្នកលឿង និងស្ពានឆ្លងកាត់សមុទ្រ (កោះកុង កំពង់សោម)។
- ផ្លូវទឹក: រួមមានបណ្តាញទន្លេមេគង្គ បឹងទន្លេសាប រហូតដល់សមុទ្រ និងមានកំពង់ផែ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងកំពត។
- ផ្លូវអាកាស: រួមមានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្រុងសៀមរាប ក្រុងព្រះសីហនុ។

**-វិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ:** ប្រាក់រៀលគឺជាតំណាងឱ្យរូបិយប័ណ្ណជាតិ និងមានរូបិយប័ណ្ណបរទេសផ្សេងៗដូចជា ប្រាក់ដុល្លា ប្រាក់អឺរ៉ូ ប្រាក់បាត ប្រាក់យ៉េន ដែលចរាចរណ៍លើទីផ្សារ (១ដុល្លាអាមេរិច ប្រហែល ៤០០០រៀល)។

**-វិស័យអប់រំ:** រួមមានគ្រឹះស្ថានអប់រំសាធារណៈ និងឯកជន តាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ក្នុងនោះសាលារៀនរដ្ឋមានចំនួន ១១,០៤៦ គ្រឹះស្ថានបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សាមានចំនួន ៩៧ ដែលក្នុងនោះ សាធារណៈចំនួន ៣៨ និងឯកជនចំនួន ៥៩ សរុបសិស្ស-និស្សិតសិក្សាក្នុងឆ្នាំសិក្សា ២០១២-២០១៣ មានចំនួន ៣,៥០០,០០០ នាក់។

**-វិស័យទេសចរណ៍:** កម្ពុជាសម្បូរទៅដោយតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រជាច្រើនដូចជា: ប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ដែលបានចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក និងតំបន់រមណីយដ្ឋានធម្មជាតិ គីរីរម្យ ភ្នំបូកគោ ភ្នំគូលែន ជម្រកសត្វស្លាបបឹងទន្លេសាប ព្រៃរនាម តំបន់ទឹកធ្លាក់ និងតំបន់មាត់សមុទ្ររួមមាន ឆ្នេរកែប ឆ្នេរកោះកុង (ព្រៃកោងកាង) ឆ្នេរក្រុងព្រះសីហនុ ដែលជាប់ជាឆ្នេរសមុទ្រស្អាតបំផុតលើពិភពលោក។

**វប្បធម៌ សិល្បៈ** រួមមានរបាំអប្សរា របាំព្រះរាជទ្រព្យ ល្ខោនស្បែកធំ ដែលជាសម្បត្តិបេតិកភណ្ឌអរូបីរបស់ពិភពលោក ក្រៅពីនេះនៅមានក្បូរក្បាច់ចម្លាក់នៅតាមប្រាង្គប្រាសាទ ព្រះវិហារ និងគ្រឿងចម្លាក់លំអផ្សេងៗ ដែលតំណាលពីរឿងព្រេង និងទេវកថាទៅតាមសម័យកាលនីមួយៗ។

**សាសនា** មានសាសនាបីធំៗដូចជា ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋមានប្រជាជន ៩០% គោរពប្រតិបត្តិ និងមានវត្តសរុប ៤,៣៩២វត្ត មានព្រះសង្ឃសរុបចំនួនជាង ៥០,០០០អង្គ។ គ្រឹស្តសាសនា មានប្រជាជនគោរពប្រតិបត្តិប្រមាណ ៦% និងឥស្លាមសាសនា ៤%។

# Brief Information on the Kingdom of Cambodia

The Kingdom of Cambodia is the oldest country in Southeast Asia of the Indochina Peninsula, which has a well-known civilization and culture. It was divided into 13 important Eras as follows:

1. Nokor Phnom or Funan Era (1st Century to 550)
2. Chenla Era (550 - 802)
3. Angkor Era (802 - 1432)
4. Chaktomuk Era (1432 - 1516)
5. Longvek Era (1516 - 1593)
6. Uddong Era (1620 - 1863)
7. French Colonial Period (1863 - 1953)
8. Popular Socialist Community (1953 - 1970)
9. Khmer Republic Regime (Lon Nol) (1970 - 1975)
10. Democratic Kampuchea Regime (Pol Pot) (1975 - 1979)
11. People's Republic of Kampuchea (1979 - 1989)
12. The State of Cambodia Regime (1989 - 1993)
13. The Kingdom of Cambodia following the constitution (1993 - Present)

Cambodia has an area of 181,035 square kilometers, which is divided into 23 provinces, 26 towns and 1 capital (Phnom Penh) and it has 9 Khans, 204 Sangkats, 159 districts, 1,417 communes, and 14,073 villages. The total population is about 14 million with a density of 77 people per square kilometer, and is bordered by Vietnam to the east and the south, Thailand to the west and the north, Laos to the north, and the Gulf of Thailand to the southwest.

Cambodia is located in the tropical zone with wet and dry climate, so there are two seasons; the rainy and dry season. The dry season starts from November to April, which has temperature between 24°C-33°C; and the rainy season starts from May to October, which has temperature between 18°C-30°C. The coldest month is January and the hottest is April. The annual rainfall is between 100 and 150 centimeters.

Cambodia is one of the 10 members of the Association of Southeast Asian Nations (ASEAN).

**STATE MANAGEMENT**

Cambodia is divided into 4 main institutions: the Royalty Institution, Legislative Body, Executive Body, and Judicial Institution. It implements the policy of multi-party freedom and democracy with 5-year terms per election. Elections include Non-General and General election. Non-General election is the Commune/Sangkat council election, which is elected by people. Members of the Commune/Sangkat council who win have the right to vote for members of the Senate; and General election is the National Assembly Election, which is elected by people. Members of the National Assembly who win have the right to form the government.

- **The Royalty Institution**: The king reigns, but he does not govern, and he shall be chosen by nine members of the throne council: they are the president of the Senate, the president of the National Assembly, the Prime Minister, two monks of highest positions (Samdech Sangs of Mohanikay and Thamayuth), both vice-presidents of the Senate and both vice-presidents of the National Assembly. The king, who is crowned, has to be at least 30 years up and descended from the lineage of the king of Ang Doung, Norodom, and Sisowath.

- **Legislative Body**: It includes the Senate with 63 seats and the national assembly with 123 seats which are formed by general election and non-general election.

- **Executive Body**: It is led by the Royal Government of Cambodia, which is elected by national assembly for each term with 50%+1 vote, and the government has to implement according to the constitution which the national assembly has approved. The Royal Government has a Cabinet of the Prime Minister (Peace Building), a council of ministers (Friendship Building), 25 ministries, 11 national authorities, 2 Secretaries of State, which are under its supervision.

- **Judicial Institution:** It is in charge of the administration of justice, including provincial-municipal courts or first instance court, court of appeal, Supreme Court; and the supreme council of the Magistracy, which is chaired by the king, who has the right to pardon criminals.

**THE GROSS DOMESTIC PRODUCT (GDP)**: 7% of 2011 GDP of Cambodia was derived from important sectors as follows:

- **Real Estate and Construction Sector**: During these few years, the real estate and construction sector such as land and housing developments and different construction activities are increasing at a surprising rate. There are many grand hotels, high buildings for lease or sale, and there are many companies which have bought the land to develop into a city in which there are many apartments for sale with reasonable prices in a commercial area so that people can afford them. Those cities and provinces are growing rapidly.

- **Commercial Sector**: The commercial sector includes the export of the clothes to the international markets including the USA, European Union and other agricultural products such as rubbers, rice and cassavas and the import of construction equipment, steel, cement, vehicles and other equipment.

- **Industrial Sector**: The industrial sector consists of the investment in garment industry with about 300 factories and 400,000 workers and the petroleum discovered in the sea and the hydropower in Kamchhay Mountain, Kirirom Mountain and Stung Tatai.

- **Agricultural Sector**: It is with 80% of the population being farmers, they grow rice, crops, plantations, and there are concessions and preservation of forests which are habitats of wild animals and the capture of rainfalls. In fisheries, there are fresh water fishing, marine fishing and aquaculture.

- **Transportation Sector**: It is divided into land routes, waterways, and airways.

  • **Land Routes**: There are seven national roads which link Phnom Penh City to other provinces or cities which stretch a total of 38,257 km with two overhead bridges, (Monivong and 7 Makara), Monivong twin bridge, Chroy Chongvar bridge, Prek Phnov bridge, Prek Kdam Bridge, Prek Tamak Bridge, Kisona Bridge, Se Kong bridge (Stung Treng), Neak Leaung bridge, and the bridges that span across the sea (Koh Kong and Sihanoukville).

  • **Waterways**: The network of waterways includes Mekong River and Tonle Sap Lake till the sea, and there are Phnom Penh Port, Krong Preah Sihanouk Port and Krong Kampot Port.

  • **Airways**: There are Phnom Penh International Airport, Siem Reap International Airport, and Preah Sihanouk Airport.

- **Economical and Financial Sector**: The Riel is the national currency and there are other foreign currencies in use in the market such as US Dollars, Euros, Thai Baht, and Japanese Yen. (USD 1 ~ 4,000 Riels).

- **Educational Sector**: There are public and private institutions from primary to higher education institutions with 11,046 public schools, which include 97 higher institutions consisting of 38 public and 59 private institutions, with a total of 3,500,000 students for the academic year 2012-2013.

- **Tourism Sector**: Cambodia is rich in tourism, cultural, and historical sites such as Angkor Wat Temples, Preah Vihear Temple, which are registered as world heritage sites, and natural resorts such as Kirirom, Bokor Mountain, Kulen Mountain; habitats for wild animals at Tonle Sap, inundated forests, waterfalls, sea beaches such as Kep, Koh Kong (mangroves), Preah Sihanouk Bay which is recognized as the most beautiful bay in the world.

**CULTURE AND ARTS** include Apsara dancing, Dance of Royal wealth, and grand shadow puppet dancing which are recognized as world cultural abstractive heritage. In addition, there are many carvings on temples and other sculptures which describe ancient legends and deities for different eras.

**RELIGION**: There are three main religions practiced including Buddhism, which is the state religion with 90% of the population as followers, with 4,392 pagodas. There are a total of 50,000 Buddhist monks. 6% of the populations are Christians and 4% are Muslims.

# សៀមរាប

## ៣ថ្ងៃ ២យប់ / 98$

**ចាប់ពី ១៥នាក់ឡើងទៅ តម្លៃអាចពិភាក្សាបាន**

ខេត្តសៀមរាបគឺស្ថិតនៅភាគពាយព្យនៃប្រទេសកម្ពុជា ដែលជាទឹកដីអង្គរដ៏រុងរឿង។ មានចំងាយផ្លូវ ៣១៤គម ពីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ឆ្លងកាត់ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ ខេត្តសៀមរាបមានផ្ទៃក្រឡា ១០,២៩៩គម² ស្រុកចំនួន១១ ឃុំចំនួន១០០ ភូមិចំនួន៩០៧ និងមានប្រជាជនចំនួន ៨៩៦,៤៤៣នាក់ (៨៧នាក់/គម²) ហើយមានទីក្រុងឈ្មោះថា ក្រុងសៀមរាប។ ចំពោះជីវភាពរស់នៅរបស់ប្រជាជន ៧៣% គឺជាកសិករដែលទទួលចំណូលពីការធ្វើស្រែ និងចំការ ដូចជាដាំឈូក សណ្តែក ជាដើម។ ប្រជាជនក្នុងក្រុងសៀមរាបក៏បានទទួលចំណូលបន្ថែមពីវិស័យទេសចរណ៍ផងដែរ។ ខេត្តសៀមរាប មានតំបន់ទេសចរណ៍ទាក់ទាញជាច្រើនដូចជា ប្រាសាទអង្គរវត្ត ដែលបានចាត់ចូលជាបេតិកភណ្ឌពិភពលោកដោយអង្គការយូនេស្កូ ប្រាសាទបន្ទាយស្រីដែលជាប្រាសាទដែលមានក្បាច់ចំលាក់ល្អដាច់គេ និងប្រាសាទជាច្រើនទៀត។

### ថ្ងៃទី១ ភ្នំពេញ - សៀមរាប

- ម៉ោង៦ព្រឹកចេញដំណើរឆ្ពោះទៅកាន់ខេត្តសៀមរាប
- ទទួលទានអាហារពេលព្រឹកនៅពិភពចន្ទី (ស្គន់)
- ចូលទស្សនាប្រាសាទគុហានគរ និងភ្នំសន្ទុកដែលស្ថិតក្នុងទឹកដីខេត្តកំពង់ធំ
- ទទួលទានអាហារថ្ងៃត្រង់នៅភោជនីយដ្ឋានក្នុងខេត្តកំពង់ធំ
- បន្តដំណើរតាមផ្លូវជាតិលេខ៦ឆ្ពោះទៅកាន់ក្រុងសៀមរាប
- ទស្សនាជាដំបូងនៅសារមន្ទីរជាតិអង្គរ
- ទទួលទានអាហារពេលល្ងាច និងជូនទៅផ្សាររាត្រី
- ជូនទៅសំរាកនៅសណ្ឋាគារ។

### ថ្ងៃទី២ សៀមរាប

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ
- បន្តទស្សនាក្រុងអង្គរធំ ប្រាសាទបាយ័ន ប្រាសាទបាពួន ទីលានជល់ដំរីជាដើម។
- ទទួលទានអាហារថ្ងៃត្រង់នៅមុខអង្គរក្បែរកន្លែងជិះបាឡុង (ចំណាយផ្ទាល់ខ្លួនរាល់ការជិះបាឡុង)
- ទស្សនាភូមិវប្បធម៌ជាមួយកម្មវិធីយ៉ាងច្រើនក្នុងភូមិ
- ទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានបែបប៊ូហ្វេ មុននឹងជូនទៅសំរាកនៅសណ្ឋាគារ។

### ថ្ងៃទី៣ សៀមរាប - ភ្នំពេញ

- ទស្សនាថ្ងៃរះនៅអង្គរវត្ត
- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ
- ទស្សនាប្រាសាទអង្គរវត្ត
- ទស្សនា និងទិញទំនិញនៅផ្សារចាស់ក្រុងសៀមរាប
- ទទួលអាហារថ្ងៃត្រង់នៅភោជនីយដ្ឋានក្នុងក្រុង មុននឹងធ្វើដំណើរនិវត្តមកទីក្រុងភ្នំពេញវិញ។

# Siem Reap

## *3 days 2 nights / 98$*

**For 15 people upwards, prices are negotiable**

Siem Reap is located in the northwest of Cambodia, is the land of prosperous Angkor. It is 314 kilometers from Phnom Penh city via National Road No 6 across Kandal, Kampong Cham and Kampong Thom provinces. This province covers 10,299 square kilometers and is subdivided into 11 districts, 100 communes, and 907 villages with 896,443 people residing in (Density is 87 per sq. km.). The city of this province is called "Siem Reap city" followed by its province's name. 73% of people are working in agriculture including rice, lotus, and beans, whereas other people earn their income from tourism. There are many attractive tourist sites such as Angkor Wat Temple which is inscribed as World Heritage by UNESCO, Banteay Srei Temple which has stupendous carved sculptures, and other impressing temples.

### Day 1 Phnom Penh - Siem Reap

- 6:00am depart Phnom Penh for Siem Reap
- Breakfast at Piphop Chanty (Skun)
- On the way, visit Kuhak Nokor Temple and Santok Mountain
- Lunch at local restaurant in the city center
- Continue trip to Siem Reap
- Start the visit to Angkor National Museum in the heart of the city
- Dinner at local restaurant and transfer to Siem Reap night market.
- Transfer to hotel.

### Day 2 Siem Reap

- Breakfast in hotel
- Visit South Gate of Angkor Thom, Bayon, Baphuon and Terrace of Leper King
- Lunch at local restaurant in front of Angkor Wat near balloon ride center (balloon ride on own account)
- In the afternoon, visit Cambodian Cultural Village
- Buffet dinner at local restaurant before transfer to hotel.

### Day 3 Siem Reap - Phnom Penh

- Enjoy sunrise at Angkor Wat
- Breakfast in hotel
- Visit the great Angkor Wat temple
- End of the visit with shopping at Phsar Chas
- Lunch at local restaurant in the city and transfer by bus for the journey back to Phnom Penh.






ប្រាសាទបាយ័ន

Bayon Temple



ប្រាសាទតាព្រហ្ម

Ta Prohm Temple



ភូមិវប្បធម៌

Cultural Village



ប្រាសាទអង្គរវត្ត

Angkor Wat Temple

# ភ្នំពេញ-កំពង់ធំ-សៀមរាប

## ៣ថ្ងៃ ២យប់ / 103$

**ចាប់ពី ១៥នាក់ឡើងទៅ តម្លៃអាចពិភាក្សាបាន**

កំពង់ធំគឺជាខេត្តមួយដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា មានចំងាយផ្លូវ ១៦៨គម ពីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ កាត់តាមខេត្តកណ្ដាល និងកំពង់ចាម។ ខេត្តកំពង់ធំមានផ្ទៃដីចំនួន ១៣,៨១៤គម² បែកចេញជាស្រុកចំនួន៧ ឃុំចំនួន៨៣ និងភូមិចំនួន ៧៣២ ដែលមានប្រជាជនសរុបចំនួន ៦៣១,៤០៩នាក់ ហើយមានទីក្រុងឈ្មោះថា ក្រុងស្ទឹងសែន។ ប្រជាជនមានមុខរបរចិញ្ចឹមជីវិតជា កសិករ អ្នកនេសាទ និងអ្នកលក់ដូរ។ ខេត្តកំពង់ធំ មានកន្លែងដែលទាក់ទាញភ្ញៀវទេសចរមកទស្សនាដូចជា ភ្នំសន្ទុក ស្ទឹងព្រៃប្រស់ ប្រាសាទសំបូរព្រៃគុក ប្រាសាទអណ្ដែត ។ល។

### ថ្ងៃទី១ ភ្នំពេញ - សៀមរាប

- ម៉ោង៦:០០ព្រឹក ធ្វើដំណើរពីភ្នំពេញ ឆ្ពោះទៅកាន់ខេត្តកំពង់ធំ បន្ទាប់មកទទួលទានអាហារពេលព្រឹកនៅភោជនីយដ្ឋានពិភពថ្មី (ស្គន់)។
- ទស្សនាប្រាសាទគុហនគរ
- មកដល់ភូមិខ្មែរជិះរទេះសេះទៅទស្សនាជីវភាពរស់នៅរបស់អ្នកភូមិ
- បន្ទាប់ពីអាហារថ្ងៃត្រង់នៅភោជនីយដ្ឋានសូឡាកាហ្វេ រួចបន្តដំណើរទៅទស្សនាប្រាសាទសំបូរព្រៃគុក ហើយបន្តដំណើរឆ្ពោះទៅកាន់ខេត្តសៀមរាប
- ទទួលទានអាហារពេលល្ងាច និងជូនទៅសម្រាកនៅសណ្ឋាគារ។

### ថ្ងៃទី២ សៀមរាប

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ រួចបន្តទៅទស្សនាក្រុងអង្គរធំ ប្រាសាទបាយ័ន ប្រាសាទបាពួន និងទីលានជល់ដំរី
- ទទួលទានអាហារថ្ងៃត្រង់នៅភោជនីយដ្ឋាន និងបន្តដំណើរទៅទស្សនាភូមិវប្បធម៌
- ទទួលទានអាហារពេលល្ងាច នៅភោជនីយដ្ឋាន
- ជូនទៅសម្រាកនៅសណ្ឋាគារ

### ថ្ងៃទី៣ សៀមរាប

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ រួចបន្តទៅទស្សនា ប្រាសាទតាព្រហ្ម ប្រាសាទអង្គរវត្ត
- ទទួលទានអាហារថ្ងៃត្រង់នៅភោជនីយដ្ឋាន
- ធ្វើដំណើរត្រឡប់មកទីក្រុងភ្នំពេញវិញ។

# Phnom Penh-Kampong Thom-Siem Reap

## *3 days 2 nights / 103$*

**For 15 people upwards, prices are negotiable**

Kampong Thom is located in the northeastern part of Cambodia and it is 168 kilometers from Phnom Penh via National Road No 6 across Kandal and Kampong Cham Provinces. The province has a total land area of 13,814 square kilometers subdivided to 7 districts, 83 communes and 732 Villages. The recent population is about 631,409. The city of Kampong Thom is called Steung Sen. The People normally work as farmer, fisherman and sellers. Some tourist attractions which interest local and international visitors are Santuk Mountain, Stung Prey Pros, Sambo Prey Kuk temple and Prasat Andet Temple etc.

### Day 1 Phnom Penh - Siem Reap

- 6:00am Depart form Phnom Penh to Kampong Thom and breakfast at Piphop Chanty (Skun)
- On the way visit Kuhak Norkor temple
- Arrive Khmer Home Stay for Pony-Cart to experience the villager's lifestyle
- After lunch at Solar Cofe restaurant, visit Sambo Preykuk Temple and then continue the journey to Siem Reap
- Dinner with Khmer traditional dancing and overnight in hotel.

### Day 2 Siem Reap

- Breakfast in hotel and continue to visit South Gate of Angkor Thom, Bayon, Baphuon and Terrace of Leper King
- Lunch at local restaurant
- In the afternoon visit Cambodian Cultural Village
- Dinner at local restaurant with Apsara dancing
- Transfer to hotel.

### Day 3 Siem Reap

- Breakfast in Hotel and visit Ta Phrom , Angkor Wat Temple
- Lunch at local restaurant
- Return to Phnom Penh.






ប្រាសាទបាយ័ន

Bayon Temple



ភូមិវប្បធម៌

Cultural Village




ប្រាសាទអង្គរវត្ត

Angkor Wat Temple




ប្រាសាទបាយ័ន

Bayon Temple









# សៀមរាប-ភ្នំគូលែន-បន្ទាយស្រី

# Siem Reap-Kulen-Banteay Srei

*៤ថ្ងៃ ៣យប់ / 126$*

*4 days 3 nights / 126$*

ចាប់ពី ១៥នាក់ឡើងទៅ តម្លៃអាចពិភាក្សាបាន

For 15 people upwards, prices are negotiable




## ថ្ងៃទី១ ភ្នំពេញ - សៀមរាប

- ម៉ោង៦ព្រឹកចេញដំណើររួមគ្នាឆ្ពោះទៅកាន់ខេត្តសៀមរាប និងទទួលទានអាហារពេលព្រឹកនៅពិភពចន្ទី (ស្គន់) ក្នុងខេត្តកំពង់ចាម
- ទទួលទានអាហារថ្ងៃត្រង់ក្នុងក្រុងសៀមរាប
- ទស្សនាប្រាសាទតាព្រហ្ម និងអង្គរវត្ត
- ទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានក្នុងក្រុង
- ជូនទៅសំរាកនៅសណ្ឋាគារប្រកបដោយផាសុកភាព។

## Day 1 Phnom Penh - Siem Reap

- 6:00am depart Phnom Penh for Siem Reap
- Breakfast at Piphop Chanty (Skun) in Kampong Cham province
- Lunch in the city on your arrival
- Start the visit to Ta Prohm and Angkor Wat.
- Dinner at local restaurant in town
- Transfer to hotel.



ប្រាសាទអង្គរវត្ត

Angkor Wat Temple

## ថ្ងៃទី២ សៀមរាប

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ
- ទស្សនាបារាយណ៍ទឹកថ្លា
- បន្តទស្សនាក្រុងអង្គរធំ ប្រាសាទបាយ័ន ប្រាសាទបាពួន និងទីលានជល់ដំរីជាដើម។ល។
- ទទួលទានអាហារថ្ងៃត្រង់នៅមុខអង្គរក្បែរកន្លែងជិះបាឡុង (សំរាប់អ្នកជិះបាឡុងត្រូវចំណាយផ្ទាល់ខ្លួន)
- ទស្សនាភូមិវប្បធម៌ ជាមួយកម្មវិធីជាច្រើនក្នុងភូមិ
- ទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានបែបប៊ូហ្វេ
- ជូនទៅសំរាកនៅសណ្ឋាគារប្រកបដោយផាសុកភាព។

## Day 2 Siem Reap

- Breakfast in hotel
- Visit west Baray
- Visit South Gate of Angkor Thom, Bayon, Baphuon, and Terrace of Leper King.
- Lunch at local restaurant in front of Angkor Wat near Sokha Balloon (balloon ride on own account)
- In the afternoon, visit Cambodian Cultural Village
- Buffet dinner at local restaurant
- Transfer to hotel.



ប្រាសាទបន្ទាយស្រី

Banteay Srei Temple

## ថ្ងៃទី៣ សៀមរាប

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ
- ធ្វើដំណើរតាមរថយន្តទៅទស្សនាឧទ្យានជាតិភ្នំគូលែន
- ទទួលទានអាហារថ្ងៃត្រង់នៅលើកំពូលភ្នំគូលែនកន្លែងទឹកធ្លាក់
- ពេលរសៀលទស្សនាប្រាសាទបន្ទាយស្រី
- ទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានបែបប៊ូហ្វេ។
- ជូនទៅសំរាកនៅសណ្ឋាគារប្រកបដោយផាសុកភាព។

## Day 3 Siem Reap

- Breakfast in hotel
- An excursion to Phnom Kulen
- Lunch at restaurant on top of the mountain near waterfall
- Visit Banteay Srei Temple
- Buffet dinner is served at local restaurant
- Transfer to hotel.



បារាយណ៍ទឹកថ្លាខាងលិច

West Baray

## ថ្ងៃទី៤ សៀមរាប - ភ្នំពេញ

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ
- ទស្សនាបឹងទន្លេសាប និងការរស់នៅរបស់ប្រជាជន
- ទស្សនាផ្សារចាស់ដើម្បីទិញទំនិញ និងវត្តអនុស្សាវរីយ៍
- ទទួលទានអាហារថ្ងៃត្រង់នៅភោជនីយដ្ឋានក្នុងក្រុងមុននឹងធ្វើដំណើរនិវត្តមកទីក្រុងភ្នំពេញវិញ។

## Day 4 Siem Reap - Phnom Penh

- Breakfast in hotel
- Visit Tonle Sap (floating village)
- Continue to Phsar Chas for shopping
- Lunch at local restaurant in the city before returning to Phnom Penh.



ឧទ្យានជាតិភ្នំគូលែន

Kulen National Park







# ប្រាសាទព្រះវិហារ

## ៣ថ្ងៃ ២យប់ / 104$

**ចាប់ពី ១៥នាក់ឡើងទៅ តម្លៃអាចពិភាក្សាបាន**

ខេត្តព្រះវិហារស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា ដែលមានព្រំប្រទល់ជាប់ប្រទេសឡាវនិងប្រទេសថៃ។ មានចំងាយផ្លូវ ២៩៤គម ពីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ និងលេខ៦២ កាត់តាមខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តកំពង់ធំ។ ខេត្តនេះមានក្រឡាផ្ទៃ ១៣,៧៨៨គម² មានស្រុកចំនួន៧ ឃុំចំនួន៤៩ ភូមិចំនួន២០៨ និងមានប្រជាជនចំនួន ១៧១,១៣៩ នាក់។ ខេត្តព្រះវិហារមានទីក្រុងឈ្មោះថា ក្រុងត្បែងមានជ័យ ចំពោះជីវភាពរស់នៅរបស់ប្រជាជននៅទីនោះគឺ ៨៥% ជាកសិករ និង ១៥% ជាអ្នកនេសាទ។ រីឯតំបន់ទេសចរណ៍ដែលទាក់ទាញក្នុងខេត្តនេះមានដូចជា ប្រាសាទព្រះខ័នកំពង់ស្វាយ ប្រាសាទកោកបេង ប្រាសាទព្រះវិហារ ដែលត្រូវបានចាត់ចូលជាបេតិកភណ្ឌពិភពលោកនៅឆ្នាំ២០០៨ ដោយអង្គការយូនេស្កូ ។ល។

### ថ្ងៃទី១ ភ្នំពេញ - អន្លង់វែង

- ម៉ោង៥ព្រឹកចេញដំណើរពីទីក្រុងភ្នំពេញឆ្ពោះទៅកាន់ក្រុងសៀមរាប
- ទទួលទានអាហារពេលព្រឹកនៅពិភពចន្ទី (ស្គន់)
- ទទួលទានអាហារថ្ងៃត្រង់ក្នុងក្រុងសៀមរាប
- បន្តដំណើរឆ្ពោះទៅកាន់អន្លង់វែងដើម្បីទស្សនាព្រំដែនកម្ពុជា-ថៃ ផ្នូរប៉ុលពត និងផ្ទះតាម៉ុក ជាដើម។
- ទទួលទានអាហារពេលល្ងាច និងសំរាកនៅផ្ទះសំណាក់ក្នុងស្រុកអន្លង់វែង។

### ថ្ងៃទី២ អន្លង់វែង - ព្រះវិហារ

- ទទួលទានអាហារពេលព្រឹកនៅភោជនីយដ្ឋាន
- បន្តដំណើរទៅទស្សនាប្រាសាទព្រះវិហារ
- ទទួលទានអាហារថ្ងៃត្រង់បែបពិចនិច
- ពេលរសៀល ត្រឡប់ពីប្រាសាទឆ្ពោះទៅកាន់ក្រុងសៀមរាប
- ទទួលទានអាហារពេលល្ងាចនៅភោជនីយដ្ឋានបែបប៊ូហ្វេ បន្ទាប់មកជូនទៅសំរាកនៅសណ្ឋាគារ។

### ថ្ងៃទី៣ ព្រះវិហារ - ភ្នំពេញ

- ទទួលទានអាហារពេលព្រឹកនៅសណ្ឋាគារ
- ទស្សនាប្រាសាទអង្គរវត្ត និងប្រាសាទបាយ័ន
- ទទួលទានអាហារថ្ងៃត្រង់នៅភោជនីយដ្ឋាន ហើយបន្តដំណើរត្រឡប់មកភ្នំពេញ។

# Preah Vihear Temple

## *3 days 2 nights / 104$*

**For 15 people upwards, prices are negotiable**

Preah Vihear is located in northern Cambodia with borders to Laos and Thailand. It's approximately 294 kilometers away from Phnom Penh capital city via National Road No 6 and 62 across Kandal, Kampong Cham and Kampong Thom provinces. It covers an area of 13,788 square kilometers subdivided into 7 districts, 49 communes, and 208 villages. The recent population is about 171,139. The city of Preah Vihear is called Phnom Tbeng Meanchey. It is statistically reported that 85% of people live on farming and the remaining 15% live on fishing and trading. Preah Vihear is well-known for its hotspots such as Preah Khan Kompong Svay Temple, Kork Beng Temple and Preah Vihear Temple, which has been inscribed as World Heritage in 2008 by UNESCO.

### Day 1 Phnom Penh - Anlong Veng

- 5:00 am departure from Phnom Penh to Siem Reap
- Breakfast at Piphop Chanty (Skun)
- Lunch at local restaurant in Siem Reap
- Arrival at Anlong Veng, visit Cambodia-Thai border, Pol Pot grave and Ta Mok house
